# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមិថុនា ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារទស្សនាទានស្តីពី "គម្រោងមូលនិធិគាំពារសុខុមាលភាពមន្ត្រីរាជការ"

នារសៀលថ្ងៃពុធ ៤រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំសហការីចូលរួមកិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារទស្សនាទានស្តីពី "គម្រោងមូលនិធិគាំពារសុខុ-មាលភាពមន្ត្រីរាជការ" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង្ស ស៊ីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដោយមានការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពកិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារទស្សនាទានស្តីពី "គម្រោងមូលនិធិគាំពារសុខុមាលភាពមន្ត្រីរាជការ"។

## មាតិកា


- កិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារទស្សនាទានស្តីពី "គម្រោងមូលនិធិគាំពារសុខុមាលភាពមន្ត្រីរាជការ" ទំព័រទី១
- កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច" ទំព័រទី២
- កិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពី "ទស្សនកិច្ចដើម្បីសាកល្បងពិនិត្យ និងវាយតម្លៃដល់ទីកន្លែងលើកិច្ចការផ្លាស់ប្តូរព័ត៌មានតាមការស្នើសុំ" ទំព័រទី២
- ពិធីដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ទំព័រទី៣
- កិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រកាសស្តីពី "ការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង" ទំព័រទី៣
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៣ ទំព័រទី៣
- កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ទំព័រទី៤
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី៤
- ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការក្រុមហ៊ុន ហាវត្រាសឃែភីថល អ៊ិនវេសមិន ឯ.ក (HAOTRUST CAPITAL INVESTMENT CO., LTD.) ទំព័រទី៥
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយវិទ្យាស្ថានខេមអេដ ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរជំនួយបច្ចេកទេសក្នុងក្របខណ្ឌវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៥
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០ ទំព័រទី៦
- ប្រជុំពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តគម្រោងប្រចាំខែមិថុនា ឆ្នាំ២០២៣ ទំព័រទី៧
- កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី៧




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច"

នាព្រឹកថ្ងៃពុធ ៤ រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានសហការជាមួយក្រុមហ៊ុនមេធាវី ខេមជីន រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច" ដោយមានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោក ង៉ា ខួនគា** ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេធាវី ខេមជីន និង **ឯកឧត្តម រស់ មុនិន្ទ**: ជាមេធាវីទទួលបានអាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គលឯករាជ្យពី **ន.ប.ធ.**។ កម្មវិធីបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច នីតិវិធីលក្ខខណ្ឌតម្រូវ និងការបំពេញបែបបទសម្រាប់ការស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ច ដើម្បីឱ្យមានអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដល់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ក្រុមហ៊ុនមេធាវី ខេមជីន។




រូបភាពកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការ ការគ្រប់គ្រង និងការត្រួតពិនិត្យប្រតិបត្តិការបរធនបាលកិច្ច"។

## កិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពី "ទស្សនកិច្ចដើម្បីសាកល្បងពិនិត្យ និងវាយតម្លៃដល់ទីកន្លែងលើកិច្ចការផ្លាស់ប្តូរព័ត៌មានតាមការស្នើសុំ"

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច អមដោយមន្ត្រីជំនាញ និង **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានចូលរួមធ្វើបទបង្ហាញ និងពិភាក្សាក្នុងកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពី "ទស្សនកិច្ចដើម្បីសាកល្បងពិនិត្យ និងវាយតម្លៃដល់ទីកន្លែងលើកិច្ចការផ្លាស់ប្តូរព័ត៌មានតាមការស្នើសុំ" នៅសណ្ឋាគារភ្នំពេញ ដែលសហការរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ និងវេទិកាសកលស្តីពីតម្លាភាព និងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធធនាគារអភិវឌ្ឍន៍អាស៊ី មានរយៈពេល ៣ ចាប់ពីថ្ងៃទី៦-៨ ខែមិថុនា ឆ្នាំ២០២៣។ កិច្ចប្រជុំនេះ មានការចូលរួមពីជំនាញការបច្ចេកទេសរបស់ Global Forum និង ADB ព្រមទាំងតំណាងក្រសួង-ស្ថាប័ន រួមមាន៖ ក្រសួងមហាផ្ទៃ, ក្រសួងយុត្តិធម៌, ក្រសួងពាណិជ្ជកម្ម, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា, និយ័តករមូលបត្រកម្ពុជា, និយ័តករគណនេយ្យនិងសវនកម្ម, ធនាគាជាតិនៃកម្ពុជា,សមាគមធនាគារនៅកម្ពុជា, សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា, និងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា។




រូបភាពកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពី "ទស្សនកិច្ចដើម្បីសាកល្បងពិនិត្យ និងវាយតម្លៃដល់ទីកន្លែងលើកិច្ចការផ្លាស់ប្តូរព័ត៌មានតាមការស្នើសុំ"។

## ពិធីដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម

នាព្រឹកថ្ងៃអង្គារ ១០រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ឌ.**) អមដោយសហការីបានអញ្ជើញចូលរួម "ពិធីដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម" របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា។



រូបភាពពិធីដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម។

## កិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រកាសស្តីពី "ការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង"

នារសៀលថ្ងៃអង្គារ ១០រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ឌ.**) អម **លោក ហាយ សុវណ្ណ** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានដឹកនាំសហការីចូលរួមកិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រកាសស្តីពី "ការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដោយមានការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពកិច្ចប្រជុំពិភាក្សាការងារដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រកាសស្តីពី "ការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង"។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៣

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ **ឯកឧត្តម ឆន ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ឌ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៣ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោក/កញ្ញាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែឧសភា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៣។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាង គោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

នាព្រឹកថ្ងៃចន្ទ ២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាអនុប្រធានក្រុមការងារបច្ចេកទេសស្តីពី "បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃចន្ទ ២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយរដ្ឋបាលខេត្តស្វាយរៀងបានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង ឯកឧត្តម សុខ រស់ អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ែន វិបុល** អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង នៅសណ្ឋាគាររ៉ៃគោ ខេត្តស្វាយរៀង។

សិក្ខាសាលាផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ថាតើអ្វីទៅជាបរធនបាលកិច្ច? បរធនបាលកិច្ចមានយន្តការ និងប្រតិបត្តិការដូចម្តេច? ធ្វើដូចម្តេចទើបការបង្កើត និងចុះបញ្ជីបរធនបាលកិច្ចមានភាពត្រឹមត្រូវ និងមានអនុលោមភាពតាមច្បាប់? សិក្ខាសាលានេះ ក៏បានរំលេចផងដែរអំពីតួនាទី និងសារសំខាន់របស់យន្តការបរធនបាលកិច្ចក្នុងការបង្កើត និងចុះបញ្ជី និងបង្កើតទំនុកចិត្ត ក៏ដូចជាទាក់ទាញការវិនិយោគបន្ថែម ជាពិសេសចូលរួមចំណែកជំរុញដំណើរការអភិវឌ្ឍន៍គម្រោងធុរកិច្ចនានាក្នុងខេត្តស្វាយរៀង ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលាផ្សព្វផ្សាយនេះ ក៏មានការចូលរួមពីថ្នាក់ដឹកនាំ និងតំណាងអញ្ជើញមកពីស្ថាប័ន មន្ទីរ និងអង្គភាពនានានៃរដ្ឋបាលខេត្តស្វាយរៀង, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, និងសមាគមធុរកិច្ចពាក់ព័ន្ធ ព្រមទាំងតំណាងក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក, បរធនបាលក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត និងការទទួលស្គាល់ពី **ន.ប.ធ.**។



រូបភាពសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការក្រុមហ៊ុន ហាវត្រាស ឃែភីថល អ៊ិនវេសម៉ិន ឯ.ក (HAOTRUST CAPITAL INVESTMENT CO., LTD.)

នាល្ងាចថ្ងៃចន្ទ ២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមពិធីលៀងសាយភោជន៍ អបអរសាទរពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការក្រុមហ៊ុន ហាវត្រាស ឃែភីថល អ៊ិនវេសម៉ិន ឯ.ក (HAOTRUST CAPITAL INVESTMENT CO., LTD.) ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ក្រុមហ៊ុន ហាវត្រាស ឃែភីថល អ៊ិនវេសម៉ិន ឯ.ក ជាក្រុមហ៊ុនបរធនបាល ដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចពាណិជ្ជកម្ម បរធន-បាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។




រូបភាពពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការក្រុមហ៊ុន ហាវត្រាស ឃែភីថល អ៊ិនវេសម៉ិន ឯ.ក (HAOTRUST CAPITAL INVESTMENT CO., LTD.)។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយវិទ្យាស្ថានខេមអេដ ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរជំនួយបច្ចេកទេសក្នុងក្របខណ្ឌវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃពុធ ៤កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយវិទ្យាស្ថានខេមអេដ ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរជំនួយបច្ចេកទេសក្នុងក្របខណ្ឌវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **បណ្ឌិត ព្រុំ ទីរៈ** ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានខេមអេដ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ ក្នុងគោល-បំណងដើម្បីលើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងអំពីវិស័យបរធន-បាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងដើម្បីផ្តល់ការគាំទ្រ និងផ្លាស់ប្តូរជំនួយបច្ចេកទេសទៅវិញទៅមកសម្រាប់ជាវិភាគទានដល់កិច្ចដំណើរការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា។

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការចូលរួមផ្តល់បទបង្ហាញដោយមន្ត្រីជំនាញជាន់ខ្ពស់របស់ **ន.ប.ធ.** និងសាស្ត្រាចារ្យនៃវិទ្យាស្ថានខេមអេដ ព្រមទាំងមានការអញ្ជើញចូលរួមជាសក្ខីភាពពីតំណាងជាន់ខ្ពស់នៃនិយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ថ្នាក់ដឹកនាំជាន់ខ្ពស់ និងសិស្ស-និស្សិតនៃវិទ្យាស្ថានខេមអេដ តំណាងក្រុមហ៊ុនបរធនបាល តំណាងប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក តំណាងក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងស្ថាប័នជាដៃគូរបស់ **ន.ប.ធ.** ផងដែរ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាពពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយវិទ្យាស្ថានខេមអេដ ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរជំនួយបច្ចេកទេសក្នុងក្របខណ្ឌវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០

នាព្រឹកថ្ងៃចន្ទ ៩កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តី-ព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០ នៅធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា និងជាប្រធានគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក-សមាជិកា គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។



រូបភាពកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ប្រជុំពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តគម្រោងប្រចាំខែមិថុនា ឆ្នាំ២០២៣

កាលពីថ្ងៃចន្ទ ៩កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ (PIU1) **លោក ប៉ុ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃ **ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការ នៃគម្រោង ACSEP សម្រាប់សមាសភាគទី១(PIU1) បានដឹកនាំមន្ត្រីជំនាញ និងទីប្រឹក្សាជាតិ សម្រាប់សមាសភាគទី១ (PIU1) ចូលរួមកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តគម្រោងប្រចាំខែមិថុនា ឆ្នាំ២០២៣ ដែលបានរៀបចំដោយ MAFF-PMU នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។




រូបភាពប្រជុំពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តគម្រោងប្រចាំខែមិថុនា ឆ្នាំ២០២៣។

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ១៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយរដ្ឋបាលខេត្តកោះកុង បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោកជំទាវ មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្តកោះកុង នៅសាលមហោស្រព ខេត្តកោះកុង។

សិក្ខាសាលាផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ថាតើអ្វីទៅជាបរធនបាលកិច្ច? បរធនបាលកិច្ចមានយន្តការ និងប្រតិបត្តិការដូចម្តេច? ធ្វើដូចម្តេចទើបការបង្កើត និងចុះបញ្ជីបរធនបាលកិច្ចមានភាពត្រឹមត្រូវ និងមានអនុលោមភាពតាមច្បាប់? សិក្ខាសាលានេះក៏បានរំលេចផងដែរអំពីតួនាទី និងសារសំខាន់របស់យន្តការបរធនបាលកិច្ចក្នុងការបង្កើតនិងចុះបញ្ជី និងបង្កើតទំនុកចិត្ត ក៏ដូចជាទាក់ទាញការវិនិយោគបន្ថែម ជាពិសេសចូលរួមចំណែកជំរុញដំណើរការអភិវឌ្ឍន៍គម្រោងធុរកិច្ចនានាក្នុងខេត្តកោះកុង ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលាផ្សព្វផ្សាយនេះ ក៏មានការចូលរួមពីថ្នាក់ដឹកនាំ និងតំណាងអញ្ជើញមកពីស្ថាប័ន មន្ទីរ និងអង្គភាពនានានៃរដ្ឋបាលខេត្តកោះកុង, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, និងសមាគមធុរកិច្ចពាក់ព័ន្ធ ព្រមទាំងតំណាងក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក, បរធនបាលក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត និងការទទួលស្គាល់ពី **ន.ប.ធ.**។




រូបភាពកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"។